**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ២៩៣៦ លស ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា១.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដី១កន្លែងទំហំ ៨១.៥២២ (ប៉ែតសិបមួយពាន់ ប្រាំរយម្ភៃពីរ) ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិតាប៉ិប សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ដូចបង្ហាញក្នុងប្លង់បង្ហាញទីតាំងដី ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ផ្ទៃដីដែលបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នេះ ត្រូវចាត់ចែងនីតិវិធីបន្តដោយក្រសួងមហាផ្ទៃ ជាអាជ្ញាធរកាន់កាប់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រង ព្រមទាំងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ស្របតាមនីតិវិធីប្រទានកម្មជាធរមាន។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣ កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៣ ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលក្រុងបាវិត
ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់
និងភូមិបាល

**ប្លង់បញ្ជាក់ទីតាំងដីរបស់ប្រជាពលរដ្ឋចំនួន ០២ គ្រួសារ**
**នៅភូមិតាប៊ិប សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង**

កំណត់សំគាល់

១- លោក ពើយ សុខ និងនាង មាឃ ណារី មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សរ ០០៤២៣០ មានទំហំ ៣០៧៤៩ ម៉ែត្រក្រឡា
២- លោក ស្រី សុធិ និងនាង ដួង តឹម មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ
- សរ ០០៤២៣១ មានទំហំ ៣១៣០២ ម៉ែត្រក្រឡា ។
- សរ ០០៤២៣២ មានទំហំ ៣៤៣៧០ ម៉ែត្រក្រឡា ។
- ដីដែលជាប់ពាក់ព័ន្ធសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមានទំហំ៨១៧២២







មាត្រដ្ឋាន ១ : ៣០០០

| តារាងនិយាមការនៃចំណុចព្រំដី ឬ ចំណុចគោល | | |
|---|---|---|
| វាស់វែងដោយឧបករណ៍ ទំនើប | | DGPS_FC_500 |
| Projection UTM Zone 48N, Datum WGS 84 | | |
| ID | X | Y |
| 1 | 624134.59453378 | 1225687.15232288 |
| 2 | 624380.736091706 | 1225688.53958839 |
| 3 | 624444.93680882 | 1225688.90127682 |
| 4 | 624452.385415024 | 1225729.61536105 |
| 5 | 624586.908018105 | 1225716.64896661 |
| 6 | 624576.167163312 | 1225633.2848812 |
| 7 | 624466.452851612 | 1225648.70083097 |
| 8 | 624460.235141861 | 1225507.85003999 |
| 9 | 624458.314861811 | 1225485.71531962 |
| 10 | 624312.399073009 | 1225468.19280666 |
| 11 | 624193.286980772 | 1225453.88911681 |
| 12 | 624144.287036002 | 1225456.15408866 |
| 13 | 624144.195934028 | 1225509.76284152 |
| 14 | 624138.757350117 | 1225581.58247114 |
| 15 | 624360.422391017 | 1225581.25171659 |
| 16 | 624353.031913312 | 1225550.07614505 |

បានឃើញ និងឯកភាព
ថ្ងៃ............ខែ............ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
បាវិត ថ្ងៃទី............ខែ............ឆ្នាំ ២០២០
អភិបាលក្រុងបាវិត
លឹម សៀងហេង

វាស់វែង និងគូរប្លង់
ថ្ងៃ............ខែ............ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
បាវិត ថ្ងៃទី............ខែ............ឆ្នាំ ២០២០
ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងភូមិបាលក្រុងបាវិត
ម៉ុំ_ចិន្តា